**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សភារដ្ឋប្បវេណី
សំណុំរឿងរដ្ឋប្បវេណី
លេខ: ២២២
ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ១៩៩៨
**<u>សាលដីកា</u>**
លេខ: ១៦៤
ចុះថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ ១៩៩៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៧
ខែ កញ្ញា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ:
១- ឯកឧត្តម ............ ជាប្រធាន
២-លោក ................ ជាចៅក្រម
៣- លោក ................ ជាចៅក្រម
៤-លោក ................ ជាចៅក្រមរបាយការណ៍
៥-លោក ..................ជាចៅក្រម

**ក្រឡាបញ្ជី**
កញ្ញា...................

**<u>តំណាងមហាអយ្យការ</u>**
លោក ..................ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្ដឹងសាទុក្ខ ពីសាលដីកាលេខ ១១៧ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ១៩៩៨នៃសំណុំរឿងរដ្ឋប្បវេណីលេខ២២៦ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្ដឹងលសាទុក្ខឈ្មោះ តស ភេទប្រុស អាយុ ៦០ ឆ្នាំ ជាតិខ្មែរ មុខរបរសិប្បកម្មផលិតថ្នាំកូតាប ទីលំនៅភូមិថ្មីឃុំពាមប្រជ្ញោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ឪពុកឈ្មោះគឹម លី "ស"ម្ដាយឈ្មោះង៉ាន់ "ស"។

ឈ្មោះ តសបានផ្ទេរសិទ្ធិអោយឈ្មោះ ឡលភ ជាតតីយជន

នឹងចុងចម្លើយបណ្ដឹងសាទុក្ខឈ្មោះ ហស ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីធនាគារពាណិជ្ជចំកាត់ ទីលំនៅផ្ទះលេខ ០៦អឺ១ផ្លូវ១៥៤ សង្កាត់ផ្សារកណ្ដាល១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ឪពុកឈ្មោះ ហ៊ឹង ហ៊ាង "រ"ម្ដាយឈ្មោះឌឹម សារី "រ" ។

ឈ្មោះ ហស បានផ្ទេរសិទ្ធិអោយឈ្មោះ សសថរ។

**<u>កម្មវត្ថុបណ្ដឹង</u>** ៖ ប្ដឹងទាមទារប្រាក់ជំពាក់ និងការប្រាក់

តាមបណ្ដឹងសាទុក្ខលេខ ១០៤ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់ឈ្មោះ ឡលភ បានប្ដឹងមិនសុខចិត្តនិងសេចក្ដីសំរេចនៃសាលដីកាលេខ១១៧ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

តាមបណ្ដឹងសាទុក្ខលេខ១១២ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៨ របស់ឈ្មោះតស បានប្ដឹងមិនសុខចិត្ត នឹងសេចក្ដីសម្រេចនៃសាលដីកាលេខ១១៧ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២២២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី៣០.៧.១៩៩៣ របស់ឈ្មោះ តាល់ ណៃអ៊ឹម ជាប្រធានធនាគារកម្ពុជាពាណិជ្ជចំកាត់ ប្ដឹងទាមទារយករោងម៉ាស៊ីនកិនស្រូវ និង ឃ្លាំងស្ដុកស្រូវនៅភូមិឧត្ដម ឃុំព្រែកខ្សាយ "ស្រុកពាមរក៍ ខេត្តព្រៃវែង ពីឈ្មោះជាន ស្រ៊ីវ និងឈ្មោះឡុងលាភី ជាអ្នកទទួលសងដោយសំអាងហេតុថាឈ្មោះជាន ស្រ៊ីវ បានយករោងម៉ាស៊ីនកិនស្រូវ និងឃ្លាំងស្ដុកស្រូវមកដាក់បញ្ចាំនៅធនាគារដើម្បីធានារ៉ាប់រងប្រាក់ដែលឈ្មោះនេះខ្ចីចំនួន៥០.០០០ដុល្លាអាមេរិក ហើយសន្យាបង់ការប្រាក់អោយរៀងរាល់ខែ ព្រមទាំងបង្វិលដើម ក្នុងរយះពេល ៦ខែ ។ មកដល់ថ្ងៃនេះឈ្មោះនេះពុំព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនឡើយ ។

បានឃើញសាលក្រមលេខ០២ "ក" ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៦ របស់តុលាការខេត្តព្រៃវែងដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ ៖

១- ទទួលពាក់បណ្ដឹងចុះថ្ងៃទី ៣០.៧.៩៣ និង បណ្ដឹងផ្ទាល់មាត់នាពេលសវនាការរបស់ដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-អោយឈ្មោះ តស ចុងចម្លើយសងប្រាក់ដើមទៅធនាគារកម្ពុជាពាណីជ្ជចំកាត់ ជាដើមចោទចំនួន ៥០.០០០ដុល្លាអាមេរិក "ហាសិបពាន់ដុល្លាអាមេរិក" និងការប្រាក់ ១៨ភាគរយក្នុងមួយឆ្នាំ "ដប់ប្រាំបីភាគរយក្នុងមួយឆ្នាំ" គិតចាប់ពីថ្ងៃខកខានមិនបានបង់១៨.៨.៩២ រហូតដល់ថ្ងៃអនុវត្តសាលក្រមនេះ។

៣-អោយឈ្មោះតស ចុងចម្លើយសងសោហ៊ុយបង់ខាតចំនួន១.០០០ដុល្លាអាមេរិក "មួយពាន់ដុល្លាអាមេរិក" ទៅធនាគារកម្ពុជាពាណិជ្ជចំកាត់ ដើមចោទសុំលើសពីនេះបដិសេធចោល ។

៤-រឹបអូសទ្រព្យសម្បត្តិជាអចលនវត្ថុដែលចុងចម្លើយបានដាក់បញ្ចាំធនាគារមានរោងចក្រកិនស្រូវ ឃ្លាំងស្ដុកស្រូវ និង ដីដែលរោងចក្រ និង ឃ្លាំងតាំងនៅតាមប័ណ្ណសំគាលសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ អ៊ី២.០០១ ចុះថ្ងៃទី៧.១០.៩១ តាំងនៅភូមិចំបក់ ឃុំប្រាសាទ "ករអណ្ដើក" ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ទុកសំរាប់ធានាដល់សំណងទៅដើមចោទ "ធនាគារកម្ពុជាពាណិជ្ជចំកាត់" កាលបើចុងចម្លើយ គ្មានប្រាក់សង ។

កាលបើលក់ឡាយឡុងនូវទ្រព្យសម្បត្តិរឹបអូសខាងលើនេះ ហើយសងមិនគ្រប់ត្រូវដាក់គុកបង្ខំលើរូបកាយដើម្បីទារធនទ័ណ្ឌ ។

៥- បង្គាប់អោយឈ្មោះតស ចុងចម្លើយបង់ប្រាក់ប្រដាប់ក្ដីគឺ ៖ ពន្ធហ្នឹង និងពន្ធចុះបញ្ជីក្ដី ១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ សរុប៧.០០០៛ ប្រាក់នេះបានកាតយកពីប្រាក់ ៧.០០០៛ ដែលដើមចោទបានបង់រួចហើយ ។ កាលបើហួសឧទ្ធរណ៍បង្គាប់អោយចុងចម្លើយសងប្រាក់ ៧.០០០៛ នេះទៅដើមចោទវិញ និង អោយបង់ពន្ធសមាមាត្រមួយភាគរយស្មើនឹង ៥០០ដុល្លាអាមេរិក "ប្រាំរយ" ប្រាក់នេះដាក់ចូលថវិការដ្ឋ ៨០ភាគរយ ស្មើនឹង ៤០០ដុល្លាអាមេរិក "បួនរយ" បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ ភាគរយស្មើ

នឹង ១០០ ដុល្លាអាមេរិក "មួយរយ" ។ ប្រាក់នេះតម្រូវអោយដើមចោទបង់ជាមុនដែរ ទើបអោយចុងចម្លើយសងវិញជាក្រោយ ។

៦- សាលក្រមនេះជំនុំជំរះជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ។ ទុកសិទ្ធិអោយប្តឹងទាស់ ១៥ថ្ងៃ និង ប្តឹងឧទ្ធរណ៍ ២ខែ គិតពីថ្ងៃបានទទួលដំណឹងពីសាលក្រមនេះ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៧ ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៩៦ របស់ឈ្មោះតស ដែលប្តឹងជំទាស់នឹងសាលក្រមរដ្ឋប្បវេណីលេខ ០២ "ក" ចុះថ្ងៃទី ១៩ ខែ មករាឆ្នាំ ១៩៩៦ របស់តុលាការខេត្តព្រៃវែងលើសាលក្រមទាំងអស់ ។

បានឃើញសាដីការបៀបលេខ១៦ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

ចាត់បញ្ចូលឈ្មោះ ឡូលក ភេទប្រុស អាយុ៤៦ឆ្នាំ ទីលំនៅ ភូមិឧត្តម ឃុំព្រែកខ្សាយ ស្រុកពាមរក៍ ខេត្តព្រៃវែង ជាតតីយជនខាងចុងចម្លើយ ។

បានឃើញសាលដីកាលេខ ១១៧ ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៩.៣.១៩៩៦ របស់ឈ្មោះតស ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់ខុស នឹង គតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងសុំប្តឹងចូលជាតតីយជនរបស់ឈ្មោះឡូលក នាពេលសវនាការរបស់សាលាឧទ្ធរណ៍ក្នុងរឿងក្តីរដ្ឋប្បវេណី ២២៦ ចុះថ្ងៃទី ៣០.៤.១៩៩៧របស់សាលាឧទ្ធរណ៍ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់ខុសនឹងគតិច្បាប់ ។

៣-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០២ "ក" ចុះថ្ងៃទី ១៩.០១.១៩៩៦ របស់តុលាការខេត្តព្រៃវែងទុកជាបានការ ។

៤- សំរេចកាត់យកប្រាក់ប្រដាប់ក្តី នៅជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀលដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រៀល និង លើអាជ្ញាធរតុលាការ ៥.០០០រៀល ។

៥- សាលដីកានេះ ជំនុំជំរះនៅថ្ងៃទី ១៩.៣.១៩៩៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៣.៣.១៩៩៨ ចំពោះមុខតំណាងធនាគារកម្ពុជាពាណិជ្ជចំកាត់ និង តតីយជនឈ្មោះឡូលក កំបាំងមុខដើមបណ្តឹងឧទ្ធរណ៍ ឈ្មោះតស ។

- សំរេចបើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១០៤ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់ឈ្មោះ ឡូលក ប្តឹងមិនសុខចិត្តនិងសេចលក្តីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញបណ្តឹងសាទុក្ខលេខ១១២ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់ឈ្មោះតស ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់សាលឧទ្ធរណ៍ទាំងមូល ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖ សាលាឧទ្ធរណ៍បានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ឡលក ជាចុងចម្លើយនិង ម្ចាស់បណ្តឹងសាទុក្ខបានឆ្លើយនៅពេលវនាការថា ៖ ចំពោះធ្វើម៉ាស៊ីនស្រូវនេះគឺខ្លួនមានហ៊ុននៅក្នុងនោះដែរតែនៅពេលធ្វើប្លង់ដីគាត់បានដាក់ឈ្មោះរបស់គាត់ហើយលួចចុះហត្ថលេខាជំនួសរូបខ្លួន ហើយក៏យករោងម៉ាស៊ីនកិនស្រូវ និង ឃ្លាំងស្តុកស្រូវទៅបញ្ចាំនៅធនាគារកម្ពុជាខពាណិជ្ជចំកាត់ ដោយខ្លួនពុំបានដឹងទាល់តែ ។ ឯនៅក្នុងលិខិតសះជាខ្លួនបានសន្យាថាសងក្នុងរយះពេលមួយឆ្នាំ ខ្លួនសុខចិត្តខាតបង់ទ្រព្យសម្បត្តិរបស់ខ្លួនដែលបញ្ចាំនោះទាំងអស់ហើយ តែគាត់នៅតែពុំព្រមហើយនៅតែប្តឹងរករឿងអោយសងជំងឺចិត្តទៀត ហើយពេលបងខ្លួនស្លាប់ទៅគេបែរជាមករឹបអូសយកទ្រព្យសម្បត្តិខ្លួនបន្ថែមទៀត តែខ្លួនបានអ្វីអោយ ។ ហើយខ្លួនឆ្ងល់ណាស់ហេតុអ្វីក៏តុលាការមិនជួយរកយុត្តិធម៌អោយខ្លួនចំពោះរឿងបងរបស់ខ្លួនលួចស៊ីញ៉េក្លែងក្លាយអោយខ្លួនផង ។

បានស្តាប់ចម្លើយរបស់ឈ្មោះសរ សុថេរិន ជាដើមចោទនិង ជាចុងបណ្តឹងសាទុក្ខ បានឆ្លើយនៅពេលសវនាការថា ៖ នៅថ្ងៃទី ០៧.៩.៩៩ បំណុលទាំងអស់ ៥ម៉ឺនដុល្លាអាមេរិកដោយមិនគិតការប្រាក់ព្រមទាំងថ្លៃជំងឺចិត្តទៀតផង ។ ហើយនៅក្នុងលទ្ធផលសះជាបើសិនជាគាត់ចូលខ្លួនមកមែននោះ ខ្លួនប្រហែលជាយល់ព្រម តែគាត់មិនចូលខ្លួនសោះ ។ ខ្លួនសំណូមពរសុំទាមទារប្រាក់៥ម៉ឺនដុល្លាអាមេរិកនិងទាមទារជំងឺចិត្ត និង ទ្រព្យសម្បត្តិដែលគាត់ប្រចាំ ព្រមទាំងការប្រាក់ទៀតផង ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាបចម្លើយ ដោះសាររបស់លោក ឡលក តតីយជន និង ជាតំណាងអោយលោក តស និងចម្លើយលោក សរ សុថេរិន តំណាងអោយធនាគារពាណិជ្ជកម្ពុជាចំកាត់
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា ៖ បណ្តឹសាទុក្ខលេខ ១០៤ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់លោក ឡលក និង បណ្តឹងសាទុក្ខលេខ ១១២ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់លោក តស ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពី ការចាត់តាំងនិង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ៖ ម៉ាស៊ីនកិនស្រូវ និង ឃ្លាំងស្តុកស្រូវព្រមទាំងដីដែលលោក ជាម ស្រីវបានដាក់បញ្ចាំនៅធនាគារកម្ពុជាពាណិជ្ជចំកាត់ពិតជាកម្មសិទ្ធិរបស់លោក ជាម ស្រីវ ប្រាកដមែន ដូច្នេះតុលាការអាចសម្រេចអោយរឹបអូសកម្មសិទ្ធិនេះដើម្បីលក់ឡាយឡុងសងបំណុលរបស់សពលោក ជាម ស្រីវបាន ។
- យល់ឃើញថា ៖ លោក តស ដែលជាឪពុករបស់សពលោក ជាម ស្រីវ ក៏បានទទួលស្គាល់បំណុលនេះ ហើយលោកក៏ត្រូវបានការប្រគល់សិទ្ធិអោយសងបំណុលនេះដែរ ។ រីឯលោក ឡលក ដែលជាតតីយជនក្នុងរឿងក្តីនេះពុំមានភស្តុតាងបញ្ជាក់ថា លោកមានចំណែកនៅក្នុងភាគហ៊ុននៃកម្មសិទ្ធិដ៍ ពោងម៉ាស៊ីនស្រូវ និង ឃ្លាំងដែលធនាគារសុំរឹបអូសនេះឡើយ ។
- យល់ឃើញថា ៖ លោក តស និង លោក ឡុក លាភី បានទទួលលិខិតបង្គាប់អោយធ្វើសារណាការពាររឿងក្តីរបស់ខ្លួនហើយ ប៉ុន្តែពុំបានធ្វើសារណាជូនមកតុលាការកំពូលតាមកំណត់ច្បាប់ទេ ។
- យល់ឃើញថា ៖ សាលដីការដ្ឋប្បវេណីលេខ ១១៧ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះមានលក្ខណះត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ១០៤ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់លោក ឡលក និង បណ្តឹងសាទុក្ខលេខ ១១២ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់លោក តែ សេង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនិងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ១១៧ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៣៨.០០០រៀល ដែលលោក តស និង លោក ឡលក បានបង់រួចហើយគឺ ៖

- ពន្ធចុះបញ្ជីក្តីនិង ពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់
- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀលសរុប ១៩.០០០រៀល នៅសល់ ១៩.០០០ រៀល បង្វិលអោយលោក តស និង លោក ឡលក ម្នាក់ពាក់កណ្តាលវិញ ។

បង្គាប់អោយលោក តស បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្តព្រៃវែង និង បង់ពន្ធសមាមាត្រ ១ភាគរយ លើការប្រាក់ និង សោហ៊ុយបង់ខាត ។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណះនៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៩ ។